01652486

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

D359/39 និង D360/48

**តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ**

សំណុំរឿងព្រហ្មទណ្ឌលេខៈ ០០៤/២/០៧-០៩-២០០៩-អវតក/កសចស (អបជ ៦០)

**អង្គបុរេជំនុំជម្រះ**

| | | |
|---|---|---|
| ចំពោះមុខ: | ចៅក្រម ប្រាក់ គឹមសាន | ជាប្រធាន |
| | ចៅក្រម Olivier BEAUVALLET | |
| | ចៅក្រម ន៉ី ថុល | |
| | ចៅក្រម Kang Jin BAIK | |
| | ចៅក្រម ហួត វុទ្ធី | |
| កាលបរិច្ឆេទ: | ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០២០ | |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 17 / 07 / 2020
ម៉ោង (Time/Heure): 12:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

**សាធារណៈ**

**សេចក្តីសម្រេចលើសំណើរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី សុំឲ្យអង្គបុរេជំនុំជម្រះ ចាត់វិធានការចាំបាច់នានា ដើម្បីធានាការពារសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២**

---

**សហព្រះរាជអាជ្ញា:**

ជា លាង
Brenda J. HOLLIS

**សហមេធាវីការពារក្តី អោ អាន:**

មុំ លុជ្ស
Richard ROGERS
Göran SLUITER

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ហុង គឹមសួន
ឡៅ ជុនធី
សំ សុគង់
ស៊ិន សុវន
ជេត វណ្ណលី
គឹម ម៉េងឃី
ទី ស្រ៊ីនណា
វ៉េន ពៅ

Emmanuel JACOMY
Martine JACQUIN
Daniel MCLAUGHLIN
Nushin SARKARATI

Laure DESFORGES
Isabelle DURAND
Lyma NGUYEN

អង្គបុរេជំនុំជម្រះ * E.C.C.C * C.E.T.C * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "សំណើរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ស្នើសុំវិធានការចាំបាច់នានារបស់អង្គបុរេជំនុំជម្រះ ដើម្បីការពារសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង០០៤/២" ដែលបានដាក់ដោយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ("សំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណី")[1]។

## I. ប្រវត្តិនីតិវិធី

1. នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះបានចេញ "សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ" ក្នុងសំណុំរឿង០០៤/២ ("សេចក្ដីពិចារណា") ដោយជូនដំណឹងទៅអង្គបុរេជំនុំជម្រះ ការិយាល័យសហចៅក្រមស៊ើបអង្កេត ការិយាល័យសហព្រះរាជអាជ្ញា មេធាវីការពារក្ដី អោ អាន និងដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២[2]។ នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះ តាមរយៈសារអេឡិចត្រូនិក បានដាក់ជូនអង្គភាពបណ្ណសារ នូវសេចក្ដីណែនាំមិនឲ្យជូនដំណឹងទៅអង្គជំនុំជម្រះសាលាដំបូង និងរក្សាទុកសំណុំរឿង ០០៤/២ ក្នុងបណ្ណសារ[3]។ នៅថ្ងៃដដែលនេះ ក្រឡាបញ្ជីមួយរូបទៀត នៃអង្គបុរេជំនុំជម្រះ បានដាក់

---

[1] សំណុំរឿង០០៤/២/០៧-០៩-២០០៩-អវតក/កសចស ("សំណុំរឿង០០៤/២") (អបជ ៦០) សំណើរបស់មេធាវីតំណាង ដើមបណ្ដឹងរដ្ឋប្បវេណី ស្នើសុំវិធានការចាំបាច់នានា របស់អង្គបុរេជំនុំជម្រះ ដើម្បីការពារសិទ្ធិរបស់ ដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ ឯកសារ D359/33 និង D360/42 ( "សំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D359/33 និង D360/42)")។ អង្គជំនុំជម្រះកត់សម្គាល់ថា មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីប្រាំបីរូប ក្នុងចំណោមមេធាវីដប់ប្រាំរូប បានដាក់សំណើនេះគឺៈ ហ៊ុង គីមសួន, ឡោ ជុនធី, សំ សុគង់ ស៊ិន សុវ៉ន Emmanuel JACOMY, Martine JACQUIN, Daniel MCLAUGHLIN និង Nushin SARKARATI។

[2] សំណុំរឿង០០៤/២ (អបជ ៦០) សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ឯកសារ D359/24 និង D360/33។

[3] សំណុំរឿង០០៤/២ (អបជ ៦០) ឧបសម្ព័ន្ធ ៥ អនុស្សរណៈអន្តរការិយាល័យ របស់ចៅក្រមអន្តរជាតិ, ROS Bophana ក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះ សេចក្ដីណែនាំពាក់ព័ន្ធការមិនជូនដំណឹង អំពីសេចក្ដីពិចារណា ទៅអង្គជំនុំជម្រះសាលាដំបូង និងការរក្សាទុកក្នុងបណ្ណសារ សំណុំរឿង០០៤/២ ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ឯកសារ D359/35.5 និង D360/44.5 ទំព័រ ២។

01652488



លិខិតមួយណែនាំដល់អង្គភាពបណ្ណសារឲ្យជូនដំណឹង ទៅអង្គជំនុំជម្រះសាលាដំបូង អំពីសេចក្តីពិចារណា[4]។

2. នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ចៅក្រម ប្រាក់ គឹមសាន ប្រធានអង្គបុរេជំនុំជម្រះ បានចេញអនុស្សរណអន្តរការិយាល័យដំបូងរបស់គាត់ ជូនទៅផ្នែកគ្រប់គ្រងតុលាការ ដោយចម្លងជូនអង្គបុរេជំនុំជម្រះ ប្រធានស្តីទី និងអនុប្រធានការិយាល័យរដ្ឋបាល ដោយបញ្ជាក់ថាមានតែផ្នែកសម្រេចសេចក្តីរួមគ្នាជាឯកច្ឆន្ទប៉ុណ្ណោះ ដែលមានអានុភាពអនុវត្ត[5]។ នៅថ្ងៃដដែលនេះ ចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះ បានចេញអនុស្សរណអន្តរការិយាល័យដំបូងរបស់ពួកគាត់ ជូនទៅប្រធានស្តីទីនិងអនុប្រធានការិយាល័យរដ្ឋបាល និងប្រធានផ្នែកគ្រប់គ្រងតុលាការ ដោយចម្លងជូនអង្គបុរេជំនុំជម្រះ ដោយបញ្ជាក់ថាត្រូវបញ្ជូនសំណុំរឿង០០៤/២ ទៅអង្គជំនុំជម្រះសាលាដំបូង ដោយអនុលោមតាមវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង ហើយថាការិយាល័យរដ្ឋបាល ត្រូវបានណែនាំឲ្យជូនដំណឹង ទៅអង្គជំនុំជម្រះសាលាដំបូង[6]។ នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ ការិយាល័យរដ្ឋបាល បានបញ្ជូនអនុស្សរណៈអន្តរការិយាល័យមួយ ជូនទៅអង្គបុរេជំនុំជម្រះ ដោយស្នើសុំការបញ្ជាក់បំភ្លឺថា តើការណែនាំមួយណាត្រូវយកមកអនុវត្តពាក់ព័ន្ធនឹងការជូនដំណឹងអំពីសេចក្តីពិចារណាទៅអង្គជំនុំជម្រះសាលាដំបូង ឬជាជម្រើសផ្សេងស្នើសុំការណែនាំមួយដែលអាចយក មកអនុវត្តបាន[7]។

---

[4] សំណុំរឿង០០៤/២ (អបជ ៦០) ឧបសម្ព័ន្ធ ៣ អនុស្សរណៈអន្តរការិយាល័យ របស់ចៅក្រមអន្តរជាតិ, Kristina O'YOUNG ក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះ សេចក្តីណែនាំពាក់ព័ន្ធការជូនដំណឹង អំពីសេចក្តីពិចារណា ទៅអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង០០៤/២ ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ឯកសារ D359/35.3 និង D360/44.3។

[5] សំណុំរឿង០០៤/២ (អបជ ៦០), អនុស្សរណៈអន្តរការិយាល័យ ចេញដោយចៅក្រម ប្រាក់ គឹមសាន ប្រធានអង្គបុរេជំនុំជម្រះ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ឯកសារ D359/34 និងD360/43("អនុស្សរណៈអន្តរការិយាល័យដំបូងរបស់ចៅក្រម ប្រាក់ គឹមសាន (ឯកសារ D359/34 និងD360/43)"។

[6] សំណុំរឿង០០៤/២ (អបជ ៦០) អនុស្សរណៈអន្តរការិយាល័យ ចេញដោយចៅក្រម Kang Jin BAIK និងចៅក្រម Olivier BEAUVALLET ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ឯកសារ D359/35 និង D360/44 ("អនុស្សរណៈអន្តរការិយាល័យដំបូងរបស់ចៅក្រម Kang Jin BAIK និងចៅក្រម Olivier BEAUVALLET (ឯកសារ D359/35 និង D360/44)"។

[7] អនុស្សរណៈអន្តរការិយាល័យ ចេញដោយការិយាល័យរដ្ឋបាល ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០។

3. នៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០ ព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ "សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំឲ្យចាត់វាល់វិធានការរដ្ឋបាល ដែលតម្រូវទាំងអស់ ដើម្បីបញ្ជូនសំណុំរឿង ០០៤/២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង"[8]។ នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ សហមេធាវីការពារក្តី អោ អាន បានដាក់ "សំណើសុំការបញ្ជាក់ថា បានចាត់វិធានការរដ្ឋបាល ដែលចាំបាច់ទាំងអស់ ដើម្បីរក្សាសំណុំរឿង ០០៤/២ ទុកក្នុងបណ្ណសារ"[9]។

4. នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះ បានបញ្ជូននូវអនុស្សរណៈអន្តរការិយាល័យលើកទីពីររបស់ពួកគាត់ ទៅភាគីនានា ដោយចម្លងជូនអង្គបុរេជំនុំជម្រះ ក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង ប្រធានស្តីទីនិងអនុប្រធានការិយាល័យរដ្ឋបាល រួមជាមួយឧបសម្ព័ន្ធដែលភ្ជាប់ជាមួយ ទាក់ទងទៅនឹងព្រឹត្តិការណ៍នានា នៅក្នុងអង្គបុរេជំនុំជម្រះ ចាប់តាំងពីមានសេចក្តីពិចារណាមក។ នៅក្នុងអនុស្សរណៈអន្តរការិយាល័យនោះ ចៅក្រមអន្តរជាតិបានបញ្ជាក់បំភ្លឺថា អង្គបុរេជំនុំជម្រះបានចាត់វាល់សកម្មភាពរដ្ឋបាលចាំបាច់នានា ដើម្បីបញ្ជូនដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) និងសំណុំរឿង០០៤/២ ទៅអង្គជំនុំជម្រះសាលាដំបូង[10]។ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ប្រធានអង្គបុរេជំនុំជម្រះ បានចេញអនុស្សរណៈអន្តរការិយាល័យលើកទីពីរ អះអាងបញ្ជាក់ឡើងវិញថា មានតែផ្នែកសម្រេចសេចក្តីជាឯកច្ឆន្ទ នៃសេចក្តីពិចារណាប៉ុណ្ណោះ ដែលមានអានុភាពអនុវត្ត[11]។

---

[8] សំណុំរឿង០០៤/២ (អបជ ៦០) សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំឲ្យចាត់វាល់វិធានការរដ្ឋបាល ដែលតម្រូវទាំងអស់ ដើម្បីបញ្ជូនសំណុំរឿង ០០៤/០២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០ ឯកសារ D359/25 និង D360/34។

[9] សំណុំរឿង០០៤/២ (អបជ ៦០) សំណើសុំការបញ្ជាក់ថា បានចាត់វិធានការរដ្ឋបាល ដែលចាំបាច់ទាំងអស់ ដើម្បីរក្សាសំណុំរឿង ០០៤/០២ ទុកក្នុងបណ្ណសារ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ ឯកសារ D359/27 និង D360/36។

[10] អនុស្សរណៈអន្តរការិយាល័យលើកទីពីរ របស់ចៅក្រមអន្តរជាតិ Kang Jin BAIK និង Olivier BEAUVALLET ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ឯកសារ D359/36 និង D360/45 ("អនុស្សរណៈអន្តរការិយាល័យលើកទីពីរ របស់ចៅក្រមអន្តរជាតិ Kang Jin BAIK និង Olivier BEAUVALLET (ឯកសារ D359/36 និង D360/45)"។

[11] សំណុំរឿង០០៤/២ (អបជ ៦០) អនុស្សរណៈអន្តរការិយាល័យលើកទីពីរ ចេញដោយចៅក្រម ប្រាក់ គឹមសាន ប្រធានអង្គបុរេជំនុំជម្រះ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ឯកសារ D359/37 និង D360/46 ("អនុស្សរណៈអន្តរការិយាល័យលើកទីពីរ របស់ចៅក្រម ប្រាក់ គឹមសាន (ឯកសារ D359/37 និង D360/46)")។

5. នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ "សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បន្ថែមអនុស្សរណៈរបស់ អ.ប.ជ ចុះថ្ងៃទី១២ និងទី១៦ ខែមីនា ទៅក្នុងសំណុំរឿង០០៤/២" ដើម្បីរក្សានូវកំណត់ត្រាពេញលេញ និងប្រកបដោយតម្លាភាពនៃសំណុំរឿង រួមទាំង "ព័ត៌មានលម្អិតនៃការជាប់គាំងផ្នែកនីតិវិធី ដែលបានកើតឡើងនៅពីក្រោយឆាកនៅ អ.វ.ត.ក នេះ"[12]។ នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់សំណើភ្លាមៗរបស់ដើមបណ្តឹងរដ្ឋប្បវេណី[13]។ នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២០ អង្គបុរេជំនុំជម្រះ បានដាក់ អនុស្សរណៈដែលបានរៀបរាប់ទាំងអស់នេះ ចូលទៅក្នុងសំណុំរឿង (ជារួមហៅថា "អនុស្សរណៈរបស់អង្គបុរេជំនុំជម្រះ") ហើយចាត់ចំណាត់ថ្នាក់ថាជាឯកសារសាធារណៈ[14]។

6. នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២០ ចៅក្រមអង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីថ្លែងការណ៍ជាសាធារណៈរួម ពាក់ព័ន្ធសំណុំរឿង០០៤/២ ដោយបញ្ជាក់ថាអង្គជំនុំជម្រះ មិនមានសិទ្ធិចូលពិនិត្យសំណុំរឿង០០៤/២ ទេ ដោយមិនមានការជូនដំណឹង និងការបញ្ជូនសំណុំរឿងមកអង្គជំនុំជម្រះសាលាដំបូង[15]។ បន្ថែមលើនេះ ទោះបីជាចៅក្រមអន្តរជាតិ នៃអង្គជំនុំជម្រះសាលាដំបូង ជឿជាក់ថាអង្គជំនុំជម្រះសាលាដំបូង មាន "សិទ្ធិអំណាចពិសេស" ដើម្បីដោះស្រាយបញ្ហាក់ជាក់លាក់ ប៉ុន្តែចៅក្រមជាតិជឿជាក់ថា បញ្ហាត្រូវបានបិទបញ្ចប់ នៅចំពោះមុខអង្គបុរេជំនុំជម្រះ ហើយថា "នឹងពុំមានការជំនុំជម្រះក្តីលើសំណុំរឿង ០០៤/២ ពាក់ព័ន្ធ អោ អាន នៅពេលនេះ ឬនៅ

---

[12] សំណុំរឿង០០៤/២ (អបជ ៦០) សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បន្ថែមអនុស្សរណៈរបស់ អ.ប.ជ ចុះថ្ងៃទី១២ និងទី១៦ ខែមីនា ទៅក្នុងសំណុំរឿង០០៤/២ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ ឯកសារ D359/32 និង D360/41។

[13] សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D359/33 និង D360/42)។

[14] *សូមមើល* អនុស្សរណៈអន្តរការិយាល័យដំបូងរបស់ចៅក្រម ប្រាក់ គីមសាន (ឯកសារ D359/34 និងD360/43) អនុស្សរណៈអន្តរការិយាល័យដំបូង របស់ចៅក្រមអន្តរជាតិ Kang Jin BAIK និង Olivier BEAUVALLET ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ឯកសារ D359/35 និង D360/44), អនុស្សរណៈអន្តរការិយាល័យលើកទីពីរ របស់ចៅក្រមអន្តរជាតិ Kang Jin BAIK និង Olivier BEAUVALLET (ឯកសារ D359/36 និង D360/45), អនុស្សរណៈអន្តរការិយាល័យលើកទីពីរ របស់ចៅក្រម ប្រាក់ គីមសាន (ឯកសារ D359/37 និង D360/46) (ជារួម "អនុស្សរណៈអន្តរការិយាល័យ របស់អង្គបុរេជំនុំជម្រះ (ឯកសារD359/34 និង D360/43 ឯកសារ D359/35 និង D360/44 ឯកសារ D359/36 និង D360/45 ឯកសារ D359/37 និង D360/46)")។

[15] សំណុំរឿង០០៤/២ សេចក្តីថ្លែងការណ៍របស់ ចៅក្រមអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ស្តីពីសំណុំរឿង ០០៤/២ ពាក់ព័ន្ធ អោ អាន ថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០ https://eccc.gov.kh/en/articles/statement-judges-trial-chamber-eccc-regarding-case-0042-involving-ao (ចូលមើលនៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២០)។

ពេលអនាគតឡើយ”[16]។ នៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់បណ្តឹងឧទ្ធរណ៍ភ្លាមៗ ប្រឆាំងការរំលត់ជាធរមាននូវសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ដែលត្រូវបានជូនដំណឹងដោយអង្គជំនុំជម្រះតុលាការកំពូល នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២០[17]។

7. នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ សហមេធាវីការពារក្តី អោ អាន បានដាក់ “សំណើសុំដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ” ទៅការិយាល័យសហចៅក្រមស៊ើបអង្កេត[18]។ នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ អគ្គលេខាធិការអង្គការសហប្រជាជាតិ បានតែងតាំងឡើងនូវនូវលោក Michael BOHLANDER ជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅការិយាល័យសហចៅក្រមស៊ើបអង្កេត នៅ អ.វ.ត.ក[19]។ នៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ សហចៅក្រមស៊ើបអង្កេត បានចេញអនុស្សរណៈមួយ ជូនដំណឹងថា ពួកគាត់ផ្អាកការចេញសេចក្តីសម្រេច លើសំណើរបស់សហមេធាវីការពារក្តី អោ អាន ជាបណ្តោះអាសន្នសិន ដោយរង់ចាំសាលដីកាសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ទៅលើបណ្តឹងសាទុក្ខភ្លាមៗ[20]។

8. នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ អង្គបុរេជំនុំជម្រះបានចេញ “សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹង

---

[16] សំណុំរឿង០០៤/២ សេចក្តីថ្លែងការណ៍របស់ ចៅក្រមអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ស្តីពីសំណុំរឿង ០០៤/២ ពាក់ព័ន្ធ អោ អាន ថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០ https://eccc.gov.kh/en/articles/statement-judges-trial-chamber-eccc-regarding-case-0042-involving-ao (ចូលមើលនៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២០)។

[17] សំណុំរឿង០០៤/២, បណ្តឹងសាទុក្ខជាបន្ទាន់របស់ សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងការរំលត់ជាធរមាន នៃសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២០ ឯកសារ E004/2/1 (“បណ្តឹងសាទុក្ខជាបន្ទាន់ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងការរំលត់ជាធរមាន របស់អង្គជំនុំជម្រះសាលាដំបូង នៃសំណុំរឿង០០៤/២ (ឯកសារE004/2/1)”)

[18] សំណុំរឿង០០៤/២ សំណើសុំដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ ឯកសារ D363

[19] សេចក្តីថ្លែងការណ៍ ការបន្តតំណែងឡើងវិញ ចំពោះសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០ https://eccc.gov.kh/en/articles/statement-international-co-investigating-judge-reinstated (ចូលមើលនៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២០)

[20] អនុស្សរណៈអន្តរការិយាល័យ របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ ឯកសារ D364។

រដ្ឋប្បវេណី”[21]។ អង្គបុរេជំនុំជម្រះបានសម្រេចជាឯកច្ឆន្ទថា អង្គជំនុំជម្រះមិនអាចរកសម្លេងគាំទ្រពីចៅក្រមយ៉ាងតិចបួនរូបបានឡើយ[22]។ ចៅក្រមជាតិពិចារណាថា អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី គួរត្រូវបានបដិសេធ[23] ចំណែកចៅក្រមអន្តរជាតិបានសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គងលើចំណុចមួយចំនួន ហើយគួរតែទទួលយកអ្នកដាក់ពាក្យសុំ តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី១២រូប[24]។ អនុលោមតាមវិធាន ៧៧ (១៣)(ក) នៃវិធានផ្ទៃក្នុង ចៅក្រមអន្តរជាតិពិចារណាថា គោលជំហរគឺថាដីកាសម្រេច គឺដីកាសម្រេចរបស់សហចៅក្រម ស៊ើបអង្កេតអន្តរជាតិ លើភាពអាចទទួលយកបាន នៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវមានសុពលភាព[25]។

## II. សារណា

9. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានលើកឡើងថា សហមេធាវី “មានកាតព្វកិច្ចលើកឡើង ពីការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ និងម្តងហើយម្តងទៀត ទៅលើសិទ្ធិក្នុងការទទួលបានសវនាការរបស់ដើមបណ្តឹងរដ្ឋប្បវេណី សិទ្ធិក្នុងការទទួលបានតំណាង សិទ្ធិទទួលបានសច្ចភាពគតិយុត្តិ និងសិទ្ធិទទួលបានតម្លាភាព និងភាពជាសាធារណៈនៃកិច្ចដំណើរការនីតិវិធីទាំងអស់

---

[21] សំណុំរឿង០០៤/២, សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចអំពី ភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំ តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី D362/6, (“សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាសម្រេចលើ ភាពអាចទទយលយកបាន (ឯកសារ D362/6)”) ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០។

[22] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាសម្រេចលើ ភាពអាចទទយលយកបាន (ឯកសារ D362/6) ផ្នែក VI. ផ្នែកសម្រេចសេចក្តី ទំព័រ ១២។

[23] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាសម្រេចលើ ភាពអាចទទយលយកបាន (ឯកសារ D362/6) កថាខណ្ឌ ៤១-៤៣។

[24] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាសម្រេចលើ ភាពអាចទទយលយកបាន (ឯកសារ D362/6) កថាខណ្ឌ ១១៨ (*សូមមើលជាឧទាហរណ៍* ចៅក្រមអន្តរជាតិបានសម្រេចថា បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី គឺអាចទទួលយកបាន ហើយសម្រេចបដិសេធមូលដ្ឋាន ១(ក), ១(ខ) និង ៣ ហើយតម្កល់ដោយផ្នែក និងបដិសេធដោយផ្នែក លើមូលដ្ឋាន ២, ៤ និង ៥)។

[25] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាសម្រេចលើ ភាពអាចទទយលយកបាន (ឯកសារ D362/6) កថាខណ្ឌ ១១៦-១១៨។

នេះ”[26]។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី អះអាងថាការិយាល័យរដ្ឋបាល មិនបាន អនុវត្ត “វិធានការរដ្ឋបាលចាំបាច់នៅឡើយ” ក្នុងការបញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្នុងសំណុំរឿង០០៤/២ និងសំណុំរឿងដែលជាប់ជាមួយ ទៅអង្គជំនុំជម្រះសាលាដំបូង[27] ហើយដែលសំណុំរឿង០០៤/២ ត្រូវស្ថិតក្នុងភាពជាប់គាំងផ្នែកនីតិវិធី ដែលមាន “ឥទ្ធិពលអាក្រក់ខ្លាំង ចំពោះសិទ្ធិរបស់ជនរងគ្រោះ ដូចមានចែងក្នុងអត្ថបទគតិយុត្តិរបស់ អ.វ.ត.ក”[28]។

10. មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានគូសបញ្ជាក់ពីប្រវត្តិនីតិវិធី ដែលលាយឡំគ្នាក្នុងនោះ នូវការចោទប្រកាន់ពីការរំលោភបំពានមួយចំនួន ទៅលើសិទ្ធិរបស់ពួកគេ ចាប់តាំងពីពេលចេញសេចក្តីពិចារណា[29]។ ការរំលោភបំពានទាំងនោះរួមមាន ការមិនបានទំនាក់ទំនង និង/ឬការយល់ច្រឡំក្នុងការទំនាក់ទំនង ដូចជា៖ ការមិនបានចម្លងជូននូវឯកសារទំនាក់ទំនង រវាងសហព្រះរាជអាជ្ញាអន្តរជាតិ សហមេធាវីការពារក្តី អោ អាន និង/ឬអង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធបញ្ជីឈ្មោះសាក្សី កិច្ចប្រជុំរៀបចំសវនាការដែលអាចធ្វើឡើង ឬអញ្ញត្រកម្ម[30] ការមិនទទួលបានការជូនដំណឹងដោយត្រឹមត្រូវ អំពីការដាក់ឯកសារជាក្រដាស តាមរយៈផ្នែកគ្រប់គ្រងតុលាការដោយសហព្រះរាជអាជ្ញាអន្តរជាតិ និង/ឬ សហមេធាវីការពារក្តី អោ អាន និងថាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គ្រាន់តែបានទទួលការជូនដំណឹងមិនផ្លូវការ[31] ការមិនបានទទួលការជូនដំណឹង អំពីសារអេឡិចត្រូនិកជាច្រើនពីក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង ទាក់ទងស្ថានភាពសំណុំរឿង រួមទាំងការណ៍ដែលអង្គជំនុំជម្រះសាលាដំបូងមិនអាចធ្វើសកម្មភាពលើសំណុំរឿង ០០៤/២[32] និងថាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនប៉ុណ្ណោះ ត្រូវបានចម្លងជូននូវពេលចេញអនុស្សរណៈជាច្រើនរបស់អង្គបុរេជំនុំជម្រះ[33]។

---

[26] សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D359/33 និង D360/42) កថាខណ្ឌ ២, ៤។

[27] សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D359/33 និង D360/42) កថាខណ្ឌ ៣។

[28] សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D359/33 និង D360/42) កថាខណ្ឌ ៣-៤។

[29] សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D359/33 និង D360/42) កថាខណ្ឌ ៥-១៦។

[30] សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D359/33 និង D360/42) កថាខណ្ឌ ៩។

[31] សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D359/33 និង D360/42) កថាខណ្ឌ ១០។

[32] សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D359/33 និង D360/42) កថាខណ្ឌ ១១, ១៣។

[33] សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D359/33 និង D360/42) កថាខណ្ឌ ១៥-១៦, ៣៤។

11. ការគោរពសិទ្ធិរបស់ជនរងគ្រោះគឺជា "ធាតុផ្សំយ៉ាងសំខាន់ សម្រាប់ការបង្រួបបង្រួមជាតិ" ហើយប្រសិនបើសំណុំរឿងមិនបន្តទៅមុខ សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខ អ.វ.ត.ក ត្រូវបាន "រំលត់"[34]។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានអះអាងបន្ថែមទៀតថា ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិទទួលបានសច្ចភាពផ្លូវច្បាប់ ដែលតម្រូវថាអង្គបុរេជំនុំជម្រះ ត្រូវចេញសេចក្តីសម្រេចដោយមានសំអាងហេតុ[35] ដោយលើកទឡ្ហីករណ៍ថា "សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ មិនបានផ្តល់សច្ចភាពផ្លូវច្បាប់"[36]។ ចាប់តាំងពីមានសេចក្តីពិចារណាមក ទាំងអង្គបុរេជំនុំជម្រះ និងស្ថាប័ននានារបស់ អ.វ.ត.ក មិនបាន "ចេញសេចក្តីពន្យល់ច្បាស់លាស់ជាសាធារណៈ ទាក់ទងនឹងស្ថានភាពនៃសំណុំរឿង ០០៤/២ ឬវិធីសាស្ត្រក្នុងការបន្តទៅមុខឡើយ" ដោយបានពន្យល់ថា អនុស្សរណៈរបស់អង្គបុរេជំនុំជម្រះ "ធ្វើឱ្យការជាប់គាំងបន្តទៅមុខទៀត"[37]។

12. មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា ជនរងគ្រោះ "មានសិទ្ធិជាសារវ័ន្តក្នុងការចូលរួមប្រកបដោយអត្ថន័យ និងដោយយុត្តិធម៌នៅគ្រប់ដំណាក់កាលទាំងអស់"[38] រួមមានតាមរយៈការតំណាងដោយ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី នៅដំណាក់កាលបុរេជំនុំជម្រះ និងសហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណី នៅដំណាក់កាលជំនុំជម្រះ[39]។ ដោយប្រើប្រាស់វិធាន ២១ នៃវិធានផ្ទៃក្នុង ដែលតម្រូវថា "ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះ ត្រូវបានការពារនៅក្នុងអំឡុងពេល នៃកិច្ចដំណើរការនីតិវិធីរឿងក្តី" មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានចោទប្រកាន់ថា ដោយសារតែមិនមានក្របខណ្ឌរដ្ឋបាល សម្រាប់ការដាក់សារណា នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនោះ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនត្រូវបានជូនដំណឹងអំពី ការវិវឌ្ឍន៍សំខាន់ៗនោះឡើយ[40]។

---

[34] សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D359/33 និង D360/42) កថាខណ្ឌ ២៣។

[35] សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D359/33 និង D360/42) កថាខណ្ឌ ២៧, ២៩។

[36] សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D359/33 និង D360/42) កថាខណ្ឌ៣០។

[37] សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D359/33 និង D360/42) កថាខណ្ឌ ៣០។

[38] សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D359/33 និង D360/42) កថាខណ្ឌ ៣១។

[39] សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D359/33 និង D360/42) កថាខណ្ឌ ៣១។

[40] សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D359/33 និង D360/42) កថាខណ្ឌ ៣២, ៣៤។

13. មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ក៏បានលើកឡើងពីបញ្ហាដែលការិយាល័យរដ្ឋបាល និងអង្គបុរេជំនុំជម្រះ "មិនទទួលស្គាល់" សហមេធាវីនាំមុខ តំណាងដើមបណ្ដឹងរដ្ឋប្បវេណី តែមួយគត់របស់តុលាការ នៅក្នុងសំណុំរឿង០០៤/២ ដែលធ្វើឲ្យខូចខាតដល់សិទ្ធិរបស់ជនរងគ្រោះ[41]។ ការណ៍នេះទើបធ្វើឲ្យមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ក្លាយជាអ្នកតំណាងតែមួយគត់ ដែលត្រូវបានទទួលស្គាល់ ប៉ុន្តែមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី "មិនមានសិទ្ធិស្វ័យប្រវត្តិ ក្នុងការដាក់សារណា" នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងឡើយ[42]។ បន្ថែមលើនេះ មាត្រា ៦៩(៣) នៃវិធានផ្ទៃក្នុងបានប្រមើលមើលអំពីការចូលរួមរបស់សហមេធាវីនាំមុខ តំណាងដើមបណ្ដឹងរដ្ឋប្បវេណី តាមរយៈការចូលពិនិត្យមើលសំណុំរឿង តាំងពីមុនសំណុំរឿង ត្រូវបានបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូងម្ល៉េះ[43]។ ការរារាំងសហមេធាវីនាំមុខ តំណាងដើមបណ្ដឹងរដ្ឋប្បវេណី មិនឲ្យចូលពិនិត្យមើលសំណុំរឿង ធ្វើឲ្យដើមបណ្ដឹងរដ្ឋប្បវេណី "មិនមានភាពជាអ្នកតំណាងផ្លូវច្បាប់ដែលជាការជំរុញជាគន្លឹះ ដល់កិច្ចដំណើរការនីតិវិធីឲ្យកើតមាន"[44]។

14. មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី បានដាក់សំណើ ក, ខ, គ និង ឃ ទៅអង្គបុរេជំនុំជម្រះ ដូចខាងក្រោម៖

ក. ចេញសេចក្ដីថ្លែងការជាសាធារណៈ ឬបង្គាប់ឲ្យស្ថាប័នមានសមត្ថកិច្ចរបស់ អ.វ.ត.ក ចេញសេចក្ដីថ្លែងការណ៍ជាសាធារណៈ ស្ដីពីស្ថានភាពនៃសំណុំរឿង ០០៤/២ និងជំហានបន្ទាប់ដែលរំពឹងទុក ដើម្បីដោះស្រាយភាពជាប់គាំង ផ្នែកនីតិវិធីនាពេលបច្ចុប្បន្ន។

ខ. បង្គាប់ថា សហមេធាវីនាំមុខ តំណាងដើមបណ្ដឹងរដ្ឋប្បវេណី ទទួលបានសិទ្ធិចូលពិនិត្យមើលសំណុំរឿង នៅក្នុងដំណាក់កាលនេះ។

គ. បង្គាប់ថា ភាគីនានា អង្គជំនុំជម្រះ និងស្ថាប័នដទៃទៀតទាំងអស់របស់ អ.វ.ត.ក ត្រូវផ្ញើរជូនទៅសហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសំណុំរឿង ០០៤/២ នូវការទំនាក់

---

[41] សំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D359/33 និង D360/42) កថាខណ្ឌ ៣៧, ៣៩។

[42] សំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D359/33 និង D360/42) កថាខណ្ឌ ៣៧។

[43] សំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D359/33 និង D360/42) កថាខណ្ឌ ៣៩ ដកស្រង់ វិធាន ៦៩(៣) នៃវិធានផ្ទៃក្នុង។

[44] សំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D359/33 និង D360/42) កថាខណ្ឌ ៤០។

ទំនង និងការដាក់ឯកសារកន្លងមកទាំងអស់ ពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធី សំណុំរឿង ០០៤/២ ដែលកន្លងមកមិនបានផ្ញើរជូនពួកគាត់ រួមទាំងការដាក់ឯកសារ និងការទំនាក់ទំនងទៅអង្គជំនុំជម្រះសាលាដំបូង និង

ឃ. បង្គាប់ថា ចាប់ពីពេលនេះទៅ ភាគី អង្គជំនុំជម្រះ និងស្ថាប័នដទៃទៀតទាំងអស់របស់ អ.វ.ត.ក ត្រូវផ្ញើរជូនទៅសហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី នូវការទំនាក់ទំនង និងការដាក់ឯកសារទាំងអស់ ពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធី សំណុំរឿង០០៤/២ រហូតដល់ពេលដែល អ.វ.ត.ក បានប្រកាសទទួលស្គាល់ជាផ្លូវការ ចំពោះសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង០០៤/២[45]។

15. មិនមានភាគីណាមួយបានដាក់ចម្លើយតប ចំពោះសំណើរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីឡើយ។

## III. ការពិភាក្សា

16. ចំពោះសំណើ ក អង្គជំនុំជម្រះបានបញ្ជាក់ច្បាស់រួចហើយ នៅក្នុងអនុស្សរណៈអង្គបុរេជំនុំជម្រះថា អង្គជំនុំជម្រះបានប្រើប្រាស់នូវរាល់គ្រប់មធ្យោបាយ ដើម្បីបង្គាប់ជាឯកច្ឆន្ទ ឲ្យមានការបញ្ជូនសំណុំរឿង ទៅអង្គជំនុំជម្រះសាលាដំបូង[46]។

17. ដោយផ្អែកលើស្ថានការណ៍នេះ អង្គជំនុំជម្រះពិចារណាថា បញ្ហានៃសំណើ ខ ថាតើត្រូវផ្ដល់ ឬមិនផ្ដល់ដល់សហមេធាវីនាំមុខ តំណាងដើមបណ្ដឹងរដ្ឋប្បវេណី នូវសិទ្ធិចូលពិនិត្យសំណុំរឿង០០៤/២ នោះ មិនអាចឲ្យអង្គបុរេជំនុំជម្រះដោះស្រាយបានឡើយ នៅដំណាក់កាលនេះ។

18. ចំពោះសំណើ គ អង្គបុរេជំនុំជម្រះសូមរំឭកថា អង្គជំនុំជម្រះបានបញ្ជាក់ជាសាធារណៈ នៅក្នុងអនុស្សរណៈរបស់អង្គបុរេជំនុំជម្រះ រួមជាមួយឧបសម្ព័ន្ធ កាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២០ ដូច្នេះហើយនោះគឺជាការផ្ញើរជូនត្រឹមត្រូវទៅមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី នូវការទំនាក់

---

[45] សំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D359/33 និង D360/42) កថាខណ្ឌ ៥៨។

[46] អនុស្សរណៈអន្តរការិយាល័យ របស់អង្គបុរេជំនុំជម្រះ (ឯកសារD359/34 និង D360/43 ឯកសារ D359/35 និង D360/44 ឯកសារ D359/36 និង D360/45 ឯកសារ D359/37 និង D360/46)។ អង្គជំនុំជម្រះកត់សម្គាល់ថា អង្គជំនុំជម្រះតុលាការកំពូលបានទទួលបណ្ដឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សម្រាប់បញ្ហានានាពាក់ព័ន្ធនឹងសំណើ ក នៅក្នុងរឿងក្ដីនេះ។ *សេចក្ដីសម្រេចលើសំណើរបស់ មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី សុំឲ្យអង្គបុរេជំនុំជម្រះ ចាត់វិធានការចាំបាច់នានា ដើម្បីធានាការពារសិទ្ធិរបស់ ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២*

ទំនងនិងការដាក់ឯកសារកន្លងមកទាំងអស់ ទាក់ទងកិច្ចដំណើរការនីតិវិធី ដែលចោទជាបញ្ហា ក្នុងសំណុំរឿង០០៤/២[47]។

19. សម្រាប់សំណើ ឃ វិញ អង្គជំនុំជម្រះពិចារណាថា ការជំទាស់ទៅនឹង ការមិនអាចបំពេញកិច្ចដែលអាចកើតមាន គឺជាការទាយស្មាន មិនទាន់ដល់ពេល ដូច្នេះហើយចាំបាច់ត្រូវបដិសេធចោល។

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទៈ**

**បដិសេធ** សំណើដើមបណ្តឹងរដ្ឋប្បវេណីទាំងស្រុង។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។

**រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០២០**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** **Olivier BEAUVALLET** **ន័យ ថុល** **Kang Jin BAIK** **ហួត វុទ្ធី**

[47] អង្គជំនុំជម្រះកត់សម្គាល់ថា ការចោទប្រកាន់ពីការមិនបាន ជូនដំណឹងទៅមេធាវីតំណាង ដើមបណ្តឹងរដ្ឋប្បវេណី អំពីការទំនាក់ទំនង និងការដាក់ឯកសារ គឺមានត្រឹមតែការទំនាក់ទំនង និងការដាក់ឯកសារ ពាក់ព័ន្ធជាមួយអង្គជំនុំជម្រះសាលាដំបូងប៉ុណ្ណោះ បន្ទាប់ពីការចេញសេចក្តីពិចារណា ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩។ *សេចក្តីសម្រេចលើសំណើរបស់ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី សុំឱ្យអង្គបុរេជំនុំជម្រះ ចាត់វិធានការចាំបាច់នានា ដើម្បីធានាការពារសិទ្ធិរបស់ ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២*